# កិច្ចសម្ភាសរបស់អ៊ុស្រីឈ្មោះ ស៊ុន អ៊ី

កៈ អ្នកសម្ភាសឈ្មោះ ហេង សុជីវី ខៈ អ្នកដែលអោយគេសម្ភាសឈ្មោះ ស៊ុន អ៊ីម

កៈ ចាស ដំបូងជម្រាបសួរអ៊ុំ!
ខៈ ចាសជម្រាបសួរ!
កៈ ចាស! អ៊ុំថ្ងៃនេះខ្ញុំមានឳកាសដែលបានមកសម្ភាសអ៊ុំផ្ទាល់ ហើយខ្ញុំធ្វើការស្ម័គ្រនៅខាង គម្រោងរបស់សាលា BYU នៅខាងសហរដ្ឋអាមេរិច ហើយគម្រោងរបស់ខាងសាលាមួយហ្នឹង ចង់ជួយចងក្រងពង្សប្រវត្តិប្រជាជនកម្ពុជាដែល មានវ័យចាប់ពី៣៥ឆ្នាំឡើងពីជីវិត និង បទ ពិសោធន៍របស់គាត់ដែលបានឆ្លងកាត់តាំងពីមុនមកដើម្បីទុកចែកចាយអោយ កូនចៅជំនាន់ ក្រោយគេបានស្តាប់ដែរណ៎ាអ៊ុំ។ ចាស! ហើយគម្រោងរបស់ សាលាមួយហ្នឹង គឺគេចង់ជួយ ចងក្រងអញ្ចឹង ហើយថ្ងៃហ្នឹងអឺ...ខ្ញុំមាឱកាសដើម្បីនឹងមកសម្ភាសអ៊ុំផ្ទាល់ អញ្ចឹងតើអ៊ុំនឹងធ្វើការអនុញ្ញាតអោយខ្ញុំធ្វើការថតសម្លេងរបស់អ៊ុំ និង ថតរូបរបស់អ៊ុំមិញមុនហ្នឹង ដើម្បីនឹង យកទៅដាក់នៅក្នុងវេបសាយខាងសាលា ទុកអោយកូនចៅជំនាន់ក្រោយ បានស្តាប់ដែរអ៊ុំ?
ខៈ ប្រវត្តិរបស់ខ្ញុំពីដើមមកមានអី។
កៈ ចាស!
ខៈ ជំនាន់អាពត ទៅចាំគោ ទៅច្រូតស្មៅ។
កៈ ហ្នឹងហើយ! តើអ៊ុំអនុញ្ញាតដើម្បីអោយខ្ញុំ ថតសម្លេង អ៊ុំយកទៅដាក់ ក្នុងវេបសាយអត់អ៊ុំ?
ខៈ ចាស!
កៈ ចាស! អញ្ចឹងមុនដំបូងនៃការសម្ភាស ថ្ងៃហ្នឹងទី៣១ ខែ៧ ឆ្នាំ២០១៨ ហើយការសម្ភាស មុនដំបូង សូមឈ្មោះអ៊ុំ តើអ៊ុំមានឈ្មោះអីដែរអ៊ុំ?
ខៈ ខ្ញុំឈ្មោះ ស៊ុន អ៊ីម!
កៈ ចាស! ហើយអ៊ុំឈ្មោះហ្នឹងទាំងនាមត្រកូល ទាំងអត្តសញ្ញាណប័ណ្ណអី ត្រូវទាំងអស់អ៊ុំហ្មៅ?
ខៈ ចាស ត្រូវទាំងអស់!
កៈ ហើយអ៊ុំមានឈ្មោះហៅក្រៅដែរឬទេអ៊ុំ?
ខៈ មានតែមួយហ្នឹង។
កៈ មានតែមួយទេ។ មួយហ្នឹងមានអត្ថន័យយ៉ាងម៉េចដែរចំពោះអ៊ុំ?
ខៈ មានតែមួយហ្នឹង ឈ្មោះតែប៉ុណ្ណឹង។
កៈ អញ្ចឹងហ៎អ៊ុំ?
ខៈ ចាស!
កៈ អ៊ឺ...ហើយចុះអ៊ុំមានអាយុប៉ុន្មានហើយនៅក្នុងឆ្នាំហ្នឹងអ៊ុំ?
ខៈ ខ្ញុំ៥០គត់!
កៈ ចាស!
ខៈ ចាស!
កៈ ហើយអ៊ុំអឺ...អ៊ុំកើតនៅឯណាដែរអ៊ុំ?
ខៈ កើតនៅខាងព្រែកស្ទៀតហ្នឹងដែរ ពាររាំង។
កៈ ចាសនៅភូមិឃុំអីដែរអ៊ុំ?
ខៈ ឃុំព្រែកស្ទៀត។
កៈ អូ...
ខៈ ស្រុកជាមួយគាត់ហ្នឹង។

កៈ ជាមួយគ្នា នៅក្នុងខេត្តអីដែរអ៊ុំ?
ខៈ ខេត្តពារាំង!
កៈ ចាស! ហើយអឺ...អ៊ុំចន្ទគតិ
សុរិយគតិហ្នឹងវិញអ៊ុំចាំទេថាអ៊ុំកើតនៅក្នុងឆ្នាំខ្មែរយើងនៅ ឆ្នាំមួយណាដែរ?
ខៈ អូ...ខ្ញុំអត់សូវចាំផង។ ខ្ញុំអត់សូវចេះអក្សរផង។
កៈ អញ្ចឹង?
ខៈ ចាស!
កៈ ចុះមានអត្តសញ្ញាណប័ណ្ណទេអ៊ុំ?
ខៈ គ្មានទេ! មានតែប័ណ្ណគ្រួសារ អត្តសញ្ញាណប័ណ្ណបាត់ហើយ តាំងពីខ្ញុំឈឺម្ល៉េះ។
កៈ អូ...ចាស!
ខៈ ចាស!
កៈ ចាស! អ៊ុំអញ្ចឹង...
ខៈ ខ្ញុំទៅជួលផ្ទះហ្នឹង ក៏ជ្រុះបាត់ទៅ។
កៈ អូ...ចុះអ៊ុំអត់មានទៅធ្វើថ្មីទេអ៊ុំហ៎?
ខៈ អត់ទាន់បានទៅធ្វើផង។
កៈ ចុះអឺ...សមាជិកក្រុមគ្រួសាររអ៊ុំវិញ តើគាត់អឺ...បងប្អូនអីអ៊ុំមានបងប្អូន?
ខៈ បងប្អូនមានទាំងអស់!
កៈ គាត់...អញ្ចឹងអ៊ុំជាកូនទីប៉ុន្មាននៃគ្រួសារដែរ?
ខៈ ខ្ញុំទីពីរ!
កៈ ចាស! អញ្ចឹងក្រុមគ្រួសារអ៊ុំ បងប្អូនអ៊ុំ គាត់មានឈ្មោះអីខ្លះទៅអ៊ុំ?
ខៈ បងគេ ឈ្មោះ រិន បន្ទាប់មក ខ្ញុំ បន្ទាប់ទៀតប្អូន គ្នាបួននាក់។
កៈ ហ្នឹងហើយ តើគាត់មានឈ្មោះអីខ្លះទៅអ៊ុំ?
ខៈ មួយឈ្មោះ រិន មួយទៀតហ្នឹង  ខ្ញុំ អឹម។
កៈ ចាស!
ខៈ ហើយបានមកអូន!
កៈ បីនាក់!
កៈ ប្អូនហើយបានមក រុណ!
កៈ ចាស! បួននាក់។ អញ្ចឹងស្រីប៉ុន្មាន ប្រុសប៉ុន្មានដែរអ៊ុំ?
ខៈ ស្រីពីរប្រុសពីរ!
កៈ ចាស! បងប្អូនរបស់អ៊ុំដូចជាកាលពីមុន មកដល់ឥលូវហ្នឹង
អ៊ុំចងចាំសាច់រឿងអីគេខ្លះ ជា មួយពួកគាត់?
ខៈ បងៗខ្ញុំ បងប្រុសខ្ញុំវាដឹងក្តីឡើងវាឡើងត្នោតទៅ។
កៈ អ៊ឹម!
ខៈ ឡើងត្នោតទៅៗជួយរ៉ែកទឹករ៉ែកអីទៅកាប់អុសទៅអីអញ្ចឹងណា។
មកជួយធ្វើបុណ្យហ្នឹង គ្រាម៉ែឪខ្ញុំស្លាប់ទៅ។
កៈ ចាស! អ៊ុំហើយទៅដូចជាកាលនៅក្មេងៗអ៊ុំចូលចិត្តលេងអីគេខ្លះជាមួយ
ពួកគាត់ដែរអ៊ុំ?
ខៈ លេងចាំគោ ចាំអីហ្នឹង។ នាំគ្នាលេងតែអង្គុញ លេងអីហ្នឹង។
កៈ អ៊ឹម...ចាសអ៊ុំ!
ខៈ លេងឈូង លេងអី ទៅវាលទៅអីហ្នឹង។ គេហៅលេងកូនគោនោះ។
កៈ ចាស! ចាសអ៊ុំ។ អញ្ចឹងអឺ...តាំង ពីក្មេងមកដល់ឥលូវហ្នឹងអ៊ុំ
ពួកគាត់ទាំងអស់គ្នាហ្នា សព្វថ្ងៃហ្នឹង តើគាត់នៅឯណាដែរ ហើយគាត់ធ្វើអីខ្លះទៅ
អ៊ុំ?
ខៈ គាត់នៅស្រុក។ បងប្អូនខ្ញុំនៅស្រុកទាំងអស់ នៅស្រុក នៅស្ទឹងនៅបទហ្នឹង។
កៈ ជុំគ្នាទាំងអស់?
ខៈ ជុំគ្នាទាំងអស់។ គ្នាមានប្តី មានប្រពន្ធរៀងៗខ្លួនទាំងអស់។
កៈ អូ...ឪពុកម្តាយអ៊ុំមានឈ្មោះអីដែរអ៊ុំ?

ខ៖ ឪពុកខ្ញុំឈ្មោះ អ៊ឹង សឹង ម៉ែខ្ញុំឈ្មោះ រឹម។
ក៖ ចាស! អញ្ចឹងឪពុកម្ដាយរបស់អ៊ុំឥលូវ គាត់អាយុប៉ុន្មាន ហើយ
គាត់ស្លាប់អស់ហើយ?
ខ៖ គាត់ស្លាប់មួយ ៥៣ មួយ៤០គត់។ ម្ដាយ ៤០គត់ ឪពុក៥៣។
ក៖ ចាសអ៊ុំ! អញ្ចឹងគាត់ដូចជាកាលហ្នឹងអ៊ុំមាន
ចាំអ្វីដែលទាក់ទងជាមួយនឹងគាត់ ថាគាត់កើតនៅក្នុងកន្លែងណា? គាត់កើត
ឆ្នាំណា?
ខ៖  អត់បានចាំឆ្នាំគាត់ទេ។ ប៉ុនគ្រាន់ថាគាត់នៅក្នុងអាពត
គាត់ទៅរកត្រីគាត់រកត្រីរកអីហ្នឹងតាមក្រសួងតាមអីហ្នឹង។
ក៖ ចាស!
ខ៖ ដូចម៉ែខ្ញុំ ទៅច្រូតស្រូវច្រូតអី នៅតាមក្រសួងហ្នឹងគេដែរ ជំនាន់អាពត
ក៖ ក្រសួង...ក្រសួងអីគេដែរអ៊ុំ?
ខ៖ ស្ទូងដកក្នុងជំនាន់អាពត។
ក៖ ប៉ុន្តែទៅច្រូតស្រូវនៅក្នុងក្រសួង?
ខ៖ ចាស! ជំនាន់អាពតហ្នឹង។
ក៖ មានក្រសួងដែរ?
ខ៖ មានតើ  មានក្រុមគេ មួយក្រុមៗ។
ក៖ អូ...ទៅតាមក្រសួងនៅតាមក្រុមកន្លែងកសិដ្ឋាន។
ខ៖ កាន់ក្រុមទៅកងៗចឹង ប្រាំនាក់អីចឹង បីនាក់អីចឹង។
ក៖ ចាស! ចុះកាលហ្នឹង អ៊ុំ ពុកគាត់ជាមនុស្សបែបណាដែរឪពុកម្ដាយរបស់អ៊ុំ?
ខ៖ ឪពុកខ្ញុំកំព្រីកំព្រាដែរហ្នឹង។ កម្សត់តាំងពី គាត់មិនសូវជាមាន
វេទនាដែរហ្នឹង ដល់ ពេល ខ្ញុំដឹងក្ដីទៅ  គាត់ឈឺខ្លាំង អត់ធ្វើអីកើតផងបាន
ឪពុកខ្ញុំ គាត់ឡើងត្នោតដែរហ្នឹង គាត់ដល់ លេងគាត់ឡើងលែងកើត
បានកូនខ្ញុំ។ ជីវិតធ្វើត្នោតផ្ទី...បានទិញអង្ករទិញអីចិញ្ចឹមកូន...
ក៖ ចាសអ៊ុំ!
ខ៖ ចិញ្ចឹមប្អូនចិញ្ចឹមបងអញ្ចឹងទៅតគ្នាទៅ!
ក៖ ចាស! អ៊ឹម
...អញ្ចឹងអ៊ុំមានចងចាំរឿងអីគេខ្លះដែរជាមួយនឹងឪពុកម្ដាយរបស់អ៊ុំ?
ខ៖ ចងចាំតែប៉ុណ្ណឹង!
ក៖ អ៊ឹម...
ខ៖ ចងចាំតែប៉ុណ្ណឹង។ ប្រវត្តិគាត់តែឡើងត្នោតហ្នឹង។
ក៖ ចាស!
ចុះមានបានប្រាប់គាត់អី...ដូចជាគាត់មានបានប្រាប់អ៊ុំទាក់ទងជាមួយនឹងកា
លពីគាត់នៅក្មេងៗធ្វើអីគេខ្លះទេអ៊ុំ?
ខ៖ គាត់មិនបានប្រាប់អីផង!
ក៖ អ៊ឹម...ជីដូនជីតារបស់អ៊ុំគាត់មានឈ្មោះអីដែរ
ទាំងខាងម្ដាយទាំងខាងឪពុករបស់អ៊ុំ?
ខ៖ ឈ្មោះ យ៉ែម ឈ្មោះតា អម យ៉ែម!
ក៖ ចាស! អញ្ចឹងអី...ខាងហ្នឹងឪពុកក៏ខាងម្ដាយអ៊ុំ?
ខ៖ ខាងអី...ម្ដាយ!
ក៖ ខាងម្ដាយ? ហើយចុះខាងឪពុករបស់អ៊ុំវិញ?
ខ៖ ខាងឪពុកឈ្មោះ សៅ ហើយឈ្មោះ...ខ្ញុំភ្លេចឈ្មោះ...
ក៖ ចាស! អត់អីទេអ៊ុំ។ ហើយអ៊ុំមាន...
ខ៖ នឹកមិនចេញ...
ក៖ ហើយអ៊ុំមានដឹងថាគាត់កើតនៅក្នុងឆ្នាំណាហើយទីកន្លែងដែរឬទេ?
ខ៖ ខ្ញុំអត់បានចាំថានៅត្រង់កន្លែងណាទេ(សើច) ភ្លេចបាត់ហើយ!
ក៖ អ៊ុំអត់ដឹងពីគាត់ទេហ៎?

ខ៖ ចាស! ភ្លេចអស់បាត់ហើយ។ បើ ខ្ញុំបានប្ដី ឡើង
ខ្ញុំមកចាំតែគោមកតែ...វាលៗផុតជំនាន់ អាពតដែរហ្នឹង។
ក៖ អឺម...ចាស! ហើយ...
ខ៖ ព្រឹកៗឡើងដើរប្រមូលក្មេងៗទៅរើសកស្រូវ។
ក៖ ហ្នឹងហើយអ៊ុំ!
ខ៖ ដល់ម៉ោងនាំគ្នាទៅចាំ...ម៉ោង៩ម៉ោង១០បានចេញផ្ទះ។
ក៖ ចាស!
ខ៖ ម៉ោង៨យប់អីបានដល់ផ្ទះ។
ក៖ ចាស! អញ្ចឹងក្រុមគ្រួសាររបស់អ៊ុំកាលហ្នឹងនៅខេត្តណា? យូរប៉ុន្មានដែរអ៊ុំ?
ខ៖ នៅណុង កើតនៅណុតើ។
ក៖ អឺម...ហើយដូចជាកាលហ្នឹងអ៊ុំមានសាច់ញាតិនៅក្រៅប្រទេសដែរឬទេអ៊ុំ?
ខ៖ គ្មានទេ!  មានតែនៅក្នុងស្រុកភូមិហ្នឹង។
ក៖ អូ...
ខ៖ គ្មានបងគ្មានប្អូននៅស្រុកណានឹងគេទេ មាននៅតែក្នុងហ្នឹង។
ក៖ ចាស! ហើយអញ្ចឹងអឺ...ទាក់ទងជាមួយនឹងអាពាហ៍ពិពាហ៍
អ៊ុំវិញអ៊ុំបានការដែរឬទេអ៊ុំ?
ខ៖ បានការ!
ក៖ នៅឆ្នាំណាដែរ? ពេលណាដែរណា?
ខ៖ ឆ្នាំណាទេ ខ្ញុំភ្លេចបាត់ហើយ ទាល់តែតារបស់ខ្ញុំមិញបានគាត់ចាំ(សើច)!
ក៖ អញ្ចឹងហ្ន៎? (សើច)! អញ្ចឹងអឺ...លោកតាមានឈ្មោះអីដែរត្រូវជាស្វាមីរបស់អ៊ុំ?
ខ៖ ឈ្មោះ យ៉េន ប្អូនប្ដីខ្ញុំហ្នឹង ប្អូនបង្កើត។
ក៖ ចាស!  អូ! ហើយអឺ...អាពាហ៍ពិពាហ៍ កាលហ្នឹងធ្វើឡើងដោយ
ឪពុកម្ដាយជាអ្នករៀបចំ អោយឬ ក៏ ស្រលាញ់គ្នាអ៊ុំ?
ខ៖ អត់ទេ រៀបចំម៉ែឪស្ដី។
ក៖ ចាស!
ខ៖ ចាស! ការ ដាក់ស្គរបាសអីហ្នឹង។
ក៖ ចាស?
ខ៖ កាលណុងគេច្រើនតែនេះហ្ន៎ ដាក់ស្គរបាស។
ក៖ អូ...ដាក់បាសដាក់ស្គរ។
ខ៖ ណុងហើយ!
ក៖ ហើយមាន...
ខ៖ ដាច់អាពតឡើងមានតែអាហ្នឹង។
ក៖ ចាសៗអ៊ុំ! ហើយមានហែរជំនូនដែរតើ អ៊ុំនេ៎?
ខ៖ ហែរជំនូនហែរកំណប់អញ្ចឹង។ កាតស្លាកាត់សក់អី។
ក៖ ចាស! អញ្ចឹងអ៊ុំអាចប្រាប់ខ្ញុំបានទេ កាលមុនដំបូងអ៊ុំជួបនឹងលោកតា
ត្រូវជាស្វាមីរបស់អ៊ុំ ហ្នឹង តើគាត់ជួបគ្នានៅពេលណាដែរកាលណុង?
ខ៖ គាត់ហ្នឹងនៅស្រុកភូមិជាមួយគ្នាហ្នឹង។ ទៅចាំគោចាំអីហ្នឹងទៅ ហើយម្ដាយ
ក្មេកខ្ញុំ ឪម៉ែខ្ញុំស្លាប់អស់ហើយ បានប្ដីមិនមា ប្ដីរបស់អ៊ុំខ្ញុំហ្នឹង។ អ៊ុំធំ
ខ្ញុំរៀបចំអោយទៅ។ ការអោយទៅ។
ក៖ ចាស! ចាសអ៊ុំ ហើយអញ្ចឹងដូចជាភាសាអី អ៊ុំចេះសរសេរ
អានភាសាខ្មែរយើងបានអត់?
ខ៖ ខ្ញុំអត់ចេះទេ។ ខ្ញុំរៀនបានតែថ្នាក់ទី៣ទី៤ហ្នឹង។ ខ្ញុំមកចាំគោ
មកមើលម្ដាយខ្ញុំឈឺ។ ហើយមើលក្មេងៗ ជំនាន់អាពតណុង ទៅប្រមូល
ចាំគោចាំអីណុង បានថាខ្ញុំវេទនាណាស់ និយាយ ទៅ។
ក៖ ចាស! អញ្ចឹងកាលហ្នឹងរៀនថ្នាក់ទី៣នៅសាលាណាដែរអ៊ុំ?
ខ៖ ចាស! រៀនពីក្មេងនៅស្រុកខ្ញុំហ្នឹងឯង។
ក៖ ឈ្មោះសាលាអីដែរអ៊ុំ ដឹងទេ?

ខៈ សាលាហ្នឹងនៅភូមិព្រៃកស្មៀតហ្នឹងដែរ។
កៈ សាលាបឋមអ៊ុំហ្នុំ?
ខៈ សាលាក្មេងៗយើងរៀន រៀនគ្មានបានជ្រៅជ្រះ។
កៈ តែឈ្មោះសាលាអ៊ុំភ្លេចហើយ?
ខៈ អ៊ឹម!
កៈ ចាស! ហើយអី...កាលហ្នឹងអ៊ុំមានមិត្តភក្តិជិតស្និទ្ធដែរឬទេក្នុងសាលា?
ខៈ មានតែជិតខាង អ្នករួមថ្នាក់ខ្ញុំសុទ្ធតែបងប្អូនជីដូនមួយហ្នឹង។
កៈ អូ...ហើយ...
ខៈ ទៅរៀនទៅអីជាមួយគ្នា។ ទៅចាំគោចាំអីជាមួយគ្នាហ្នឹង។
កៈ ចាស! តែមានមិត្តភក្តិជិតស្និទ្ធដែរឬទេអ៊ុំ?
ខៈ មានតែឥលូវគេការហើយអស់។
កៈ អូ...ចាស! ប៉ុន្តែអ៊ុំមានចងចាំឈ្មោះគាត់ទេ មិត្តភក្តិអ៊ុំ?
ខៈ ស្គាល់តែ ភាព ឆេង។
កៈ (សើច) ចាស!
ខៈ ប្អូន!
កៈ ចុះគាត់ កាលណុងអ៊ុំមានចងចាំរឿងអីខ្លះជាមួយមិត្តភក្តិរបស់អ៊ុំ?
ខៈ ចងចាំពួកវាទៅចាំគោចាំអីដេកជាមួយគ្នាតែចឹង។
កៈ អ៊ឹម...សប្បាយ!
ខៈ មកពីរៀន ទៅចាំគោ ទៅរកក្តាមរកខ្យង មកវិញទួលស្មៅទួលអី។ ថ្លឹងគីឡូពីណាបាន ច្រើនៗទៅ
គេទិតៀនទៅពីណាបានតិចជាងពីណាបានច្រើនជាង(សើច)លើកគុណសម្បត្តិទៅ (សើច)។ ជំនាន់អាពតហ្នឹង។
កៈ ចាសអ៊ុំ! អញ្ចឹងដូចជាអ៊ុំមានចេះភាសាក្រៅពីភាសាខ្មែរយើងទេអ៊ុំ?
ខៈ អូយ...ស្អីក៏ខ្ញុំមិនចេះដែរ។
កៈ  ហើយអ៊ុំកាលជីវិតរបស់អ៊ុំធ្វើស្រែចម្ការមុន  អ៊ុំបានធ្វើទំអ៊ុំ?
ខៈ ធ្វើតែស្រែមួយមុខហ្នឹង។
កៈ ធ្វើតែស្រែទេ? ហើយ...
ខៈ ចាស! ស្រុកខ្ញុំធ្វើតែស្រែ។
កៈ អញ្ចឹងគ្រួសារអ៊ុំជាកសិករ ជាអាជីវករ ឬក៏ជាអ្នករកស៊ី?
ខៈ ធ្វើស្រែហ្នឹងណ៎ា។
កៈ ធ្វើស្រែអ៊ឹហ៎?
ខៈ អ៊ឹម! ធ្វើទាំងអស់។
កៈ អញ្ចឹងជីវិតរបស់អ៊ុំបានធ្វើការងារអីគេខ្លះដែរ ដើម្បីចិញ្ចឹមជីវិត ដើម្បីរកកម្រៃទទួលទាន ចិញ្ចឹមជីវិត?
ខៈ ខ្ញុំកាលបើបែកអាពតមក បានមានប្តីមានអីហ្នឹង។ យើងថាចិញ្ចឹមជ្រូក ចិញ្ចឹមគោ ចិញ្ចឹមអីទៅ យើងចិញ្ចឹមគោចិញ្ចឹមអីទៅ លក់ទៅ ចិញ្ចឹជ្រូកលក់អញ្ចឹងទៅ ចិញ្ចឹមមាន់ ចិញ្ចឹមអីទៅ។
កៈ អ៊ឹម...
ខៈ ហើយអញ្ចឹងទៅខ្ញុំក៏កាលខ្ញុំរកគោរកអីខាតអស់ទៅ លក់ផ្ទះលក់សម្បែងទៅ ក៏បានមកនឹងគេមកធ្វើការនៅសំណង់ ក៏បងខ្ញុំហ្នឹងគេឱ្យមកនៅវត្តហ្នឹង ក៏លោកសុំអោយមកនៅហ្នឹងទាំង អស់គ្នាទៅ បានខ្ញុំដាំបាយស្លនៅហ្នឹងទៅ។ ខ្ញុំគ្មានផ្ទះទេ។
កៈ អ៊ឹម...
ខៈ ខ្ញុំមិនចង់និយាយទេក្មួយអើយ!
កៈ ចាសអ៊ុំ! ចាសជីវិតរបស់អ៊ុំតស៊ូទម្រាំតែបានប៉ុណ្ណឹងមកណ៎ាអ៊ុំណ៎ា? ហើយខ្ញុំសូមសរសើរអ៊ុំដែល...

ខៈ ខ្ញុំមកដល់ភ្នំពេញ ខែបុណ្យភ្ជុំបិណ្ឌហ្នឹង បេះស្លឹកបាស់បេះអីលក់ដូរ គ្រាន់បានកូនរៀន។
កៈ លក់នៅផ្សារណាដែរអ៊ុំ?
ខៈ ទួលទំពូង!
កៈ ទួលទំពូងយើង?
ខៈ កន្ត្រៀតលក់។
កៈ អ៊ឹម...
ខៈ ហើយកូនតូចៗវានាំគ្នាទៅរៀន គោកព្រះ(ឈ្មោះកន្លែង)ហ្នឹង។
កៈ អ៊ឹម...
ខៈ តែវាតស៊ូទៅរៀនបានសុទ្ធតែថ្នាកទីដប់!
កៈ ចាសអ៊ុំ!
ខៈ វាអត់លុយទេនាំគ្នាដើរ។
កៈ អ៊ឹម...ចាសអ៊ុំ!
ខៈ មកពីរៀនវិញ វានាំគ្នាទៅជួយបេះស្លឹកបាស់តាមៗរបងផ្ទះជួល គេអាណិតគេអោយបេះ ទៅ។
កៈ អ៊ឹម...ចាសអ៊ុំ! អញ្ចឹងជីវិតរបស់...
ខៈ អ៊ឹម...តែនាំនិយាយ នាំទឹកភ្នែកទេ។
កៈ (សើច) សុំទោសអ៊ុំ! តែសសើរអ៊ុំដែលខំប្រឹងតស៊ូចិញ្ចឹមកូនមករហូតហ្នឹង ព្រោះអីជីវិតត្រូវការ....
ខៈ នេះតូចជាងគេហ្នឹង
កៈ ជួបនៅការលំបាកទម្រាំតែបាន...
ខៈ ខ្ញុំជួលផ្ទះគេ ទើបបានមកនៅវត្តហ្នឹង៤ខែហើយ។ ហើយតលូវខ្ញុំឈឺទៀត។
កៈ ចុះអ៊ុំអី!អ៊ុំធ្លាប់ដូចជាកាលពីក្មេង មកដល់តលូវហ្នឹងអ៊ុំធ្លាប់បានមានការផ្លាស់ប្តូរអីគេខ្លះដែរក្នុងជីវិតរបស់អ៊ុំ?
ខៈ ហ៊ុយ! ខ្ញុំកម្សត់អញ្ចឹង នៅឯស្រុកក៏អញ្ចឹងដែរ ដើរកាប់អុស រកលុយចិញ្ចឹមប្អូន ចិញ្ចឹមបង ព្រោះឪពុកម្តាយយើងស្លាប់ចោលយើងហើយ។ មកដល់ម្តាយក្មេកឪក្មេកក៏ស្លាប់អស់ទៀត។
កៈ អ៊ឹម...
ខៈ ដល់មកធ្លាក់ខ្លួនមកនៅអញ្ចឹងទៅ។
កៈ អ៊ឹម...ចាស! ហើយចំពោះមុខម្ហូបវិញអ៊ុំចូលចិត្តមុខម្ហូបអីដែរតាំងពីក្មេងរហូតមកដល់តលូវហ្នឹង?
ខៈ មានអីបន្តិចបន្តួចស្លម្ជូរស្លអីហ្នឹង។
កៈ អូ...ស្លអីម្ហូបអីក៏អ៊ុំបានដែរអ៊ុំន៎?
ខៈ ចាស!
កៈ អញ្ចឹង...
ខៈ ជួនទៅ...ជួនទៅខ្ញុំទៅបាចត្រី ជញ្ជាត់ត្រីអីចឹងទៅ។
កៈ អ៊ឹម...
ខៈ ស្លនាំកូនចៅហូបទៅ។
កៈ ចាស! ចុះល្បែងអ៊ុំ កាលពីនៅកុមារភាព អ៊ុំចូលចិត្តលេងល្បែងអីគេខ្លះដែរអ៊ុំ?
ខៈ អត់ចេះសោះ ស្អីក៏ខ្ញុំមិនចេះដែរ។
កៈ បទចម្រៀងវិញ អ៊ុំចូលចិត្តស្តាប់ទេ?
ខៈ ចូលចិត្ត (សើច) ចូលចិត្តដែរ។ ខ្ញុំធ្លាប់មានវ៉ាគយ្ជ(វិទ្យុ) អីបើកស្តាប់ដែរ។
កៈ ចាស! បទចម្រៀងអីដែរ ដែលធ្វើអោយអ៊ុំចូលចិត្តស្តាប់ ហើយតែងតែស្តាប់មកដល់តលូវហ្នុ?
ខៈ អោយតែលឺ...អោយតែលឺគេនេះ បើកទៅលឺគេច្រៀងចេះតែបើកស្តាប់ទៅ។
កៈ ចាស! ចុះអ៊ុំចូលចិត្តបទប្រភេទអីដែរអ៊ុំ?
ខៈ បទអីក៏ខ្ញុំចូលចិត្តស្តាប់ដែរ។

កៈ សម័យ បុរាណអីក៏អ៊ុំចូលចិត្តស្តាប់ដែរអ៊ុំនំ?
ខៈ ចាស! អោយតែលឺគេច្រៀងចេះតែស្តាប់ទ។
កៈ អ្នកចម្រៀងរូបណាក៏ស្តាប់បានដែរ?
ខៈ (សើច) ចាស!
កៈ អ្នកចំរៀងរូបណាក៏ច្រៀងក៏ស្តាប់បានដែរ?
ខៈ ចាស!
កៈ ចូលចិត្តទាំងអស់ម៉ងអ៊ុំនំ?
ខៈ ហ្នឹងហើយ!
កៈ ហើយអញ្ចឹងអី...តើអ៊ុំក្រុមគ្រួសារ
ឬក៏សមាជិកក្រុមគ្រួសាររបស់អ៊ុំមានអ្នកណាគាត់ចេះលេងភ្លេងដែរឬទេអ៊ុំ?
ខៈ អត់ផង! កូនខ្ញុំគេអ្នកសុទ្ធកីឡា។
កៈ អ៊ឹម...
ខៈ នៅរៀននៅឡើយទេ!
កៈ អ៊ឹម...
ខៈ ប្រុសៗពីរហ្នឹង កីឡា អាមួយនោះវាធ្វើឡាន។
កៈ អ៊ឹម...
ខៈ អាមួយទៀតវាធ្វើកម្មករក្រុមហ៊ុន។
កៈ ចាស! អ៊ឹម...អ៊ុំ! ហើយអញ្ចឹងផ្ទះរបស់អ៊ុំកាលពីក្មេងមកដល់ឥឡូវហ្នឹងអ៊ុំមាន
ចងចាំផ្ទះហ្នឹងទេ មានលក្ខណៈម៉េចដែរ?
ខៈ ផ្ទះខ្ញុំមានតែតាខ្ញុំ លក់ រកគោខាត លក់សងគេអត់ អស់ផ្ទះមួយ។
កៈ អ៊ឹម...នៅស្រុកហ្នឹងអ៊ុំនំ?
ខៈ ចាស! អញ្ចឹងសព្វថ្ងៃនៅតែដី។
កៈ ចាស! អញ្ចឹងផ្ទះហ្នឹងធ្វើឡើងដោយឳពុកម្តាយរបស់អ៊ុំឬក៏ជួលគេទៅ?
ខៈ ផ្ទះឪក្មេកខ្ញុំលក់ ពេលដែលខ្ញុំការហើយ អញ្ចឹង
គាត់ចាស់ៗអស់ចឹងទៅក៏លក់អោយខ្ញុំចឹងទៅ ក៏មើលគាត់ទៅ ទាល់តែគាត់ស្លាប់
ទៅ។
កៈ អ៊ឹម...ការសាងសង់អីហ្នឹង កាលហ្នឹងឪពុកម្តាយរបស់អ៊ុំធ្វើ?
ខៈ គាត់ធ្វើ គាត់អ្នកធ្វើ!
កៈ អ៊ុំទាន់គាត់ធ្វើកាលណុង?
ខៈ ខ្ញុំមិនទាន់ទេ ខ្ញុំការហើយ ផ្ទះគាត់ធ្វើហើយអស់ហើយហ្នឹង។
កៈ អូ...អញ្ចឹងបងប្អូនអ៊ុំមានអ្នកណាគេដែលគាត់
ចេះជំនាញខាងវេញខាងវល្លិ៍ខាងអី...ដូចជាធ្វើស្ករត្នោតឬក៏អីមានទេ?
ឬក៏ជំនាញផ្សេងៗវិញអ៊ុំ?
ខៈ គ្មានទេ! មានតែបងខ្ញុំអ្នកធ្វើត្នោត។
កៈ គាត់ឈ្មោះអីដែរបងអ៊ុំ?
ខៈ ឈ្មោះរិន!
កៈ ចាស! ចាសអ៊ុំ ហើយអ៊ុំសព្វថ្ងៃហ្នឹងកាន់សាសនាព្រះពុទ្ធត្រូវទេអ៊ុំ?
ខៈ ចាស!
កៈ ចាស! អញ្ចឹងអ៊ុំជាពុទ្ធបរិស័ទ្ធ ហើយអី...សព្វ...អី...ការលំបាកអីគេខ្លះដែរ
ដែលអ៊ុំកាន់ សាសនាព្រះពុទ្ធ អ៊ុំមានទេ?
ខៈ មានពិបាកតែយើងតែអញ្ចឹងប៉ុណ្ណឹង។
កៈ អ៊ឹម...ចាស! ហើយអី...ការ
អ៊ុំកាន់សាសនាព្រះពុទ្ធមានអី...ផលលំបាកអីគេខ្លះដែរ?
ខៈ ខ្ញុំមិនដែលមានទៅកាន់ធម៌អីនឹងគេទេ។
កៈ ចុះសាសនាព្រះពុទ្ធបានជះឥទ្ធិពលយ៉ាងម៉េចដែរសម្រាប់ជីវិតរបស់អ៊ុំ?
ខៈ ណុងមានតែយើងមិនត្រង់ដែរ។
កៈ អ៊ឹម...ហើយអ៊ុំកាន់សាសនាព្រះពុទ្ធរយៈពេលប៉ុន្មានហើយ? យូរនៅអ៊ុំ?

ខ៖ មិនដែលមាន យើងនៅតែផ្ទះហ្នឹង។
ក៖ តែយូរហើយអ៊ុន់? កាន់តាំងពីតូចមក តាំងតែពីឪពុកម្ដាយអីមកអ៊ុន់?
ខ៖ ចាស!
ក៖ ចាស! ហើយគ្រួសាររបស់អ៊ុំកាន់សាសនាព្រះពុទ្ធទាំងអស់គ្នា?
ខ៖ យើងកាន់ យើងខ្មែរហ្នឹង។
ក៖ អ៊ឹម...បុណ្យអីខ្លះដែរដែលក្រុមគ្រួសារអ៊ុំតែងតែធ្វើ?
ខ៖ មិនដែលធ្វើអីផង។
ក៖ អត់មានធ្វើបុណ្យអីទាក់ទងនឹងព្រះពុទ្ធសាសនាយើងទេអ៊ុំហ់?
ខ៖ ធ្វើបុណ្យធ្វើតែតាមខ្មែរយើងហ្នឹង។
ក៖ អូ...ខ្មែរយើងធ្វើអីគឺខាងអ៊ុំធ្វើដែរ។
ខ៖ អ៊ឹម...
ក៖
អ៊ី...ហើយអញ្ចឹងសព្វថ្ងៃហ្នឹងអ៊ុំមានជំនឿនៅខាងព្រះពុទ្ធសាសនាកម្រិតណាដែរអ៊ុំ?
ខ៖ មិនដែលជឿអីនឹងគេផង។
ក៖ អត់ដែលជឿទេ?
ខ៖ ចាស! ខ្ញុំមិនដែលទៅនឹងគេទេ។
ក៖ អត់ដែល...អត់ដែលអី...ថ្វាយបង្គំព្រះអីទេអ៊ុំ?
ខ៖ មិនដែលទេ បើថ្វាយបង្គំខ្ញុំថ្វាយតែបង្គំយើងវត្តយើងធម្មតាហ្នឹង។
ក៖ អូ...ថ្វាយបង្គំធម្មតា តែជំនឿ ដឹងខាង...
ខ៖ ខ្ញុំក៏មិនដែល...
ក៖ បន់ស្រន់ព្រះអីទ់?
ខ៖ បើយើងបន់ស្រន់ ព្រះយើងបន់ស្រន់តែក្នុងផ្ទះយើងហ្នឹង។
ដូចថាយើងឈឺស្កាត់អីចឹងទៅណ៎ា។
ក៖ ចាស! អញ្ចឹងបញ្ហាជីវិតអីគេខ្លះដែលអ៊ុំ ជួបប្រទះពីមុនរហូតមកដល់ឥលូវ
អ៊ុំអាចប្រាប់ខ្ញុំបានឬទេ?
ខ៖ ជួបប្រទះអី ជួបប្រទះតែនឹងវេទនាពិបាក។
ក៖ ចាស!
ខ៖ ប៉ុនរកបាន ហូបចុកបន្តិចបន្តួចចឹងទៅ មានមុខរបរធំនឹងគេទេ។
ក៖ ចាសអ៊ុំ! (ដកដង្ហើមធំ) ហើយអ៊ុំឈឺអីគេខ្លះដែរសព្វថ្ងៃនេះ?
ខ៖ ខ្ញុំឈឺសួត សួតហើយគេថារបេង រោគរបេង។
ក៖ អ៊ឹម...ចាសអ៊ុំ! (ដកដង្ហើមធំ) ហើយឈឺយះរពេលប៉ុន្មានឆ្នាំហើយអ៊ុំ?
ខ៖ ទើបតែឈឺបានចូល៤ខែហ្នឹងខ្ញុំ!
ក៖ ចាស!
ខ៖ ឈឺ ចូលធ្ងន់ឈឺធ្ងន់តែម៉ង។
ក៖ ពេលធ្វើទុក្ខអ៊ុំម៉េចដែរ?
ខ៖ ក្តៅនឹងហត់!
ក៖ អ៊ឹម...ចាស! អ៊ុំហើយការចងចាំ បទពិសោធន៍
អត់ល្អអីដែលធ្វើអោយចងចាំអត់ភ្លេចសោះ ឡើយនៅក្នុងជីវិតអ៊ុំពេល
នឹកឃើញមកអ៊ុំពិបាកចិត្ត?
ខ៖ ពិបាកចិត្តត្រង់ថាអាណិតកូនអាណិតអី។ យើងអត់មានផ្ទះអត់មានសម្បែង
អោយកូននៅហ្នឹង ហើយអត់ទាន់បានរៀបកូនមួយ
ហើយអត់មានលុយមានកាក់។
ក៖ អ៊ឹម...អញ្ចឹងអ៊ី...ពេលដែលអ៊ុំពិបាកចិត្តម្តងៗអ៊ុំតែង
ធ្វើម៉េចដែរដើម្បីឱ្យបំបាត់ទុក្ខ?
ខ៖ ចេះតែលែងគិតលែដែរហ្នឹង។
ក៖ អ៊ឹម...តើអ៊ុំមានគម្រោងផែនការណ៍អីសម្រាប់ក្រុមគ្រួសារអ៊ុំដែរឬទេ?
ខ៖ សព្វថ្ងៃនេះនិយាយប្រាប់អូនឯងត្រង់ម៉ង សង្ឃឹមថាកូនវារកខ្លួនឯង។

កៈ អ៊ឹម...ចាស! ចុះទាក់ទងជាមួយនឹងអឺ...បញ្ហាអីផ្សេងៗក្នុងគ្រួសារហើយនិងអ៊ុំ
ពេលដែល ពិបាកចិត្តអញ្ចឹង អ៊ុំមានអ្នកណាគេដែលជួយអ៊ុំពីក្រោយអត់អ៊ុំ?
ខៈ អ៊ឹម...ពិបាក កូនវាមិនមានឱ្យពិបាកចិត្តអី។
កៈ អ៊ឹម...ដូចជាប្ដីអ៊ុំ ក្រុមគ្រួសារកូនអី គាត់ជួយអ៊ុំទេ?
ខៈ វាបានលុយកាក់តិចតួចវា
អោយចឹងដែរបានមើលខុសត្រូវពេលយើងឈឺស្កាត់អី កូនមកមើលទាំងអស់គ្នា។
កៈ អ៊ុំទៅពេទ្យណាដែរសព្វថ្ងៃហ្នឹង?
ខៈ ពេទ្យសម្ដេច។
កៈ គេជួយអ៊ុំទេពេទ្យហ្នឹង?
ខៈ គេថាគេយក១៥០ (ដុល្លារ)។
កៈ ទៅម្ដង អស់១៥០?
ខៈ អត់ទេ! គ្រាន់តែថ្ងៃដំបូង ហើយដល់ក្រោយមក ថ្នាំរបេងហ្នឹងគេយក១០ម៉ឺន
១១ម៉ឺន ដល់មួយខែទៅម្ដង។
កៈ អ៊ឹម...មួយខែទៅម្ដង រាល់ខែទៅ?
ខៈ ចាស!
កៈ ដើម្បីពិនិត្យមើល?
ខៈ ចាស!
កៈ ចាស! ហើយពេទ្យគេថាម៉េចដែរជម្ងឺអ៊ុំ វាអាចជាឬក៏ម៉េចដែរអ៊ុំ?
ខៈ ចាសជា!
កៈ អញ្ចឹង...
ខៈ យើងព្យាយាមហូបទៅជា។
កៈ អ៊ឹម...អ៊ុំធូរតើសព្វថ្ងៃហ្នឹង?
ខៈ ធូរ បាននិយាយកើត។
កៈ អ៊ឹម...ហើយកាលឈឺមុនដំបូងហ្នឹងវាធ្វើទុក្ខអ៊ុំយ៉ាងម៉េចដែរអ៊ុំ?
ខៈ ធ្វើក្ដៅ...ក្ដៅញ័រ យើងនិយាយអីអត់កើតទៅណ៎ា យើងក្ដៅរងាតែម៉ង។
កៈ ចាសអ៊ុំ! ចាសហើយអឺ...អញ្ចឹងដូចជាបទពិសោធន៍ល្អៗអ៊ុំវិញ
តើអ៊ុំមានបទពិសោធន៍ល្អៗ អ្វីគេខ្លះនៅក្នុងជីវិតរបស់អ៊ុំ
តាំងពីអ៊ុំនៅតូចរហូតមកដល់អ៊ុំឥលូវណ៎ាអ៊ុំ?
ខៈ តាំងពីតូចមានអី ធម្មតា ទៅដើរលេងចឹងទៅ ទៅចាំគោចាំអីទៅណ៎ា
នាំគ្នាលេងល្បែង លេងអី។
កៈ ចាស!
ហ្នឹងហើយអឺ...ដល់ពេលអញ្ចឹងអ៊ុំបទពិសោធន៍ល្អៗរបស់អ៊ុំមានដូចជាការជួបជុំ
កូនចៅក្រុមគ្រួសារ តាំងពីអ៊ុំនៅតូចដល់ពេលមកដល់ធំអីអញ្ចឹងហ្នា
អ៊ុំមានបទពិសោធន៍ល្អៗ អីគេខ្លះដែរ?
ខៈ សព្វថ្ងៃបានកូនធំទៅបានសប្បាយចិត្តបានខ្លះ។
កៈ ចាស!
ខៈ ពិបាកពីតូចៗ ដល់ពេលធំឡើង វារកខ្លួន
វាអីខ្លួនវា។កូនខ្ញុំសុទ្ធតែប្រុសៗប៉ុនៗហ្នឹងស្រីតែ មួយហ្នឹង។
កៈ អ៊ឹម...
ខៈ បានចិញ្ចឹមវារហូតមកដល់ធំទៅ វាដើររកការងារខ្លួនវាទៅ ទៅរៀន។
ព្រលឹមឡើងដើរ នាំបងប្អូនដើរ បុណ្យគេសម្រាកចឹងទៅ ទៅរៀនផ្សំៗ
ហើយវាមកធ្វើសំណងចឹងទៅ។ ខ្ញុំនឹក ឃើញកូននៅតូចៗ យកមកជួលផ្ទះគេនៅ។
កៈ អ៊ឹម...
ខៈ ហើយក្រោយមកបានខ្ញុំបានស្គាល់គេ ខ្ញុំសុំដូរគេនៅ បានគេជួយទៅបានរៀន
ហើយ នៅវត្តហ្នឹង គ្មានសល់អីទេអូនអើយ។
កៈ អ៊ឹម...អញ្ចឹងបានសព្វថ្ងៃហ្នឹងបានគាត់រៀនសូត្រអីគ្រាប់គ្នា?

ខៈ ចាស! បានកូនខ្ញុំវាបានធំៗអស់ទៅ ខ្ញុំអរខ្លះ។ ពិបាកតែខ្ញុំឈឺ បើកុំឈឺមានអី។
កៈ អ៊ឹម...ចាស! ហើយអ៊ុំប្រុសគាត់ធ្វើអីដែរសព្វថ្ងៃ?
ខៈ ចាស??
កៈ អ៊ុំប្រុសត្រូវស្វាមីអ៊ុំហ្នឹងស?
ខៈ ហ្នឹងមិញហ្នឹង មានធ្វើអី មានជួយលោកនៅហ្នឹង គាត់ជួយបោសសម្រាម នៅវត្តហ្នឹង។គាត់ធ្វើការនៅវត្ត។
កៈ ចាស! អញ្ចឹងអ៊ុំជាចុងក្រោយអ៊ុំមានពាក្យពេចន៍អីដើម្បីផ្តាំផ្ញើរទៅដល់កូនចៅជំនាន់ក្រោយដែលគេបានស្តាប់ជាពិសេសកូនចៅរបស់អ៊ុំម៉ងដែលគេបានស្តាប់នូវសម្លេងរបស់អ៊ុំសម្ភាសនៅថ្ងៃនេះអញ្ចឹងហ្នាអ៊ុំ?
ខៈ ខ្ញុំគ្រាន់តែផ្តែរផ្តាំថាអោយកូនប្រឹងប្រែងទៅ លុយកាក់អីសន្សំខ្លួនទៅកុំអោយចាយវាយ ពេកព្រោះម្តាយឈឺធ្វើអត់កើត។
ម្តាផ្តែរផ្តាំកូនចឹងទៅកន្លែងណាគេអាណិតគេស្រលាញ់ចឹងទៅណ៎ា។
កុំអោយដើរផ្លូវខុស ទៅកន្លែងណាធ្វើអោយតែគេអាណិត ខ្ញុំសព្វថ្ងៃផ្តាំកូនខ្ញុំតែចឹង។
កៈ ចាសត្រូវហើយអ៊ុំ!
ខៈ តែនិយាយទៅកូនរបស់ខ្ញុំ សុទ្ធតែមិនដែលឱ្យម៉ែឪពិបាកចិត្តទេ។
កៈ អ៊ឹម...គាត់គន្លងធម៌អ៊ុំ?
ខៈ ចាស! មិនដែលឱ្យម្តាយពិបាកទេ។
កៈ អ៊ឹម...ដូចថាអ៊ុំចង់ថាអ្នកដែលធ្វើអំពើល្អបានទទួលអំពើល្អហើយកូនចៅអីក៏សូមអោយ គាត់នៅតែ...
ខៈ បើកាលខ្ញុំឈឺនាំគ្នាទៅពេទ្យ ហើយពេទ្យថា កូនសុទ្ធតែប្រុសតែស្រុះគ្នាណាស់ ។ ពេទ្យ ស្រីៗនាំគ្នាសើច ថាកូនខ្ញុំសុទ្ធតែប្រុសៗនាំគ្នាទៅគ្រាម្តាយអមគ្រែជុំវិញ ហើយខ្ញុំនឹកឃើញ កូនទៅសប្បាយចិត្តដែរណ៎ា។
កៈ ត្រូវហើយ!
ខៈ ទោះបីលុយកាក់ខ្លះៗ មានតិចមានច្រើន។
កៈ ចាស! ក្នុងនាមជាឪពុកម្តាយតែងតែសប្បាយចិត្តពេលដែលឃើញកូនចេះគិតគូរពី ឪពុកម្តាយចឹងណ៎ាអ៊ុំ?
ខៈ ចាស!
កៈ ជាពិសេសពេលឈឺហ្នឹងម៉ង។
ខៈ ហ្នឹងហើយ!
កៈ រំពឹងជាងគេគឺរំពឹងកូនហ្នឹង។ ចាស! អញ្ចឹងអ៊ុំមានពាក្យអីផ្សេងទេដើម្បីធ្វើការផ្តាំផ្ញើរពួក គាត់ដែលជាកូនចៅជំនាន់ក្រោយ ជាពិសេសកូនអ៊ុំហ្នឹងដែរឬទេអ៊ុំ? ដើម្បីដូចថាពេលដែល គាត់បានស្តាប់សម្លេងអ៊ុំហ្នឹងទៅគាត់ដឹងថាអូ...ម៉ាក់ខ្ញុំគាត់ចង់អញ្ចេកគាត់ចង់អោយខ្ញុំហ្នឹងធ្វើអញ្ចេកៗចឹងណ៎ា  ដើម្បីនឹងទុកជា...
ខៈ អស់ហើយមានអី។ គ្រាន់ពួកវាគ្មានអោយខ្ញុំពិបាកអីផង ហ្នឹង។ វារកលុយកាក់ចឹងទៅ វាអោយខ្ញុំខ្លះទៅ វាទុកចាយខ្លួនវាខ្លះទៅ អោយវាទិញរបស់របរប្រើប្រាស់ខ្លួនវាចឹងទៅ ខោអាវចឹងទៅ ម៉ូតូអីវាទិញខ្លួនវា។
វាគ្មានអោយម្តាយទិញអោយផងហ្នឹង។
កៈ អ៊ឹម...ចាសអ៊ុំ!
ខៈ ចាស!
កៈ ចាស! អញ្ចឹងអរគុណអ៊ុំច្រើនដែលបានថ្ងៃនេះ ចំណាយពេលក្នុងកាសម្ភាសហើយជូនពរអ៊ុំ និងក្រុមគ្រួសារទាំងអស់មានសុភមង្គលអឺ...រកទទួលទានមានបានណ៎ាអ៊ុំ។
ខៈ ចាស! អរគុណអូន។ សូមអោយអូនសុខសប្បាយដែរ កុំអោយមានឈឺស្កាត់អី។
កៈ ចាស! អរគុណ៕